# ការកាត់ទោសតាមផ្លូវច្បាប់អាចបន្ធូរបន្ថយកំហឹងរបស់ប្រជាជន

*ម៉ម គល្យាន់ី*

នៅថ្ងៃសុក្រទី១៧ ខែតុលា ឆ្នាំ២០០៨ តុលាការខ្មែរក្រហមបានបដិសេធបណ្តឹងឧទ្ធរណ៍សុំនៅក្រៅឃុំរបស់អតីតមន្ត្រីក្រសួងការបរទេសរបស់ខ្មែរក្រហមដែលត្រូវចោទប្រកាន់ពីបទឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ និងឧក្រិដ្ឋកម្មសង្គ្រាម ។

អ្នកភូមិ៥០នាក់ មកពីខេត្តកំពង់ស្ពឺ កណ្តាល និងកំពត បានជួបជុំគ្នាដើម្បីស្តាប់សវនាការអង្គបុរេជំនុំជម្រះទាក់ទងនឹង អៀង សារី និងសេចក្តីសម្រេចដែលមានរយៈពេលយូរ ។

តោ សុផល ស្ត្រីម្នាក់មកពីខេត្តកំពង់ស្ពឺដែលបានបាត់បង់ប្អូនៗពីរនាក់នៅក្នុងរបបខ្មែរក្រហមចង់ដឹងថាហេតុអីបានជាមានអំពើឃោរឃៅទាំងនោះកើតឡើង ហើយតើអ្នកណាជាអ្នកទទួលខុសត្រូវចំពោះការស្លាប់របស់សមាជិកគ្រួសាររបស់នាង ។

នៅថ្ងៃនោះ តោ សុផល និងប្រជាជនដទៃទៀតពិតជាចង់ដឹងថាតើ អៀង សារី នឹងត្រូវឃុំខ្លួនឬក៏ដោះលែង ។

អៀង សារី អាយុ៨២ឆ្នាំ គឺជាសមាជិកម្នាក់ក្នុងចំណោមអ្នកដឹកនាំរបបកុម្មុយនីស្តដែលត្រូវទទួលខុសត្រូវចំពោះប្រជាជនប្រហែល១.៧លាននាក់ដែលបានស្លាប់ដោយសារការសម្លាប់ ទារុណកម្ម ភាពអត់ឃ្លាន និងការបង្ខំឲ្យធ្វើការធ្ងន់ ។

តោ សុផល ក៏ដូចជាប្រជាជនរាប់លាននាក់ផ្សេងទៀតដែរ គាត់ត្រូវបានជម្លៀសចេញពីផ្ទះ និងបង្ខំឲ្យធ្វើការធ្ងន់នៅជំរំពលកម្ម ដោយឲ្យជីកប្រឡាយ និងព្រែករហូតដល់យប់ ។ របបអាហាររបស់គាត់មានត្រឹមតែបបររាវ៣វែកក្នុងមួយថ្ងៃ ។ សុផល រៀបរាប់ពីប្អូនប្រុសអាយុ១២ឆ្នាំដែលស្លាប់ដោយអត់ឃ្លាន ។ ប្អូនរបស់ សុផល សុំឲ្យ សុផល កាត់ដៃស្តាំរបស់គាត់ចោលដើម្បីទុកជាការចងចាំ ។

ជាង៣០ឆ្នាំក្រោយមក តោ សុផល ចង់ឲ្យ អៀង សារី ស្លាប់ ។ «ហេតុអ្វីបានជា អៀង សារី ទទួលបានការព្យាបាលតាមផ្នែកវិជ្ជសាស្ត្រ រីឯគាត់និងគ្រួសាររបស់គាត់មិនទទួលបានការព្យាបាលអ្វីសោះនៅអំឡុងរបបខ្មែរក្រហម» ។

តោ សុផល មានភាពខឹងសម្បាខ្លាំងណាស់ ។

សុផល មិនជឿថាតុលាការអាចលុបបំបាត់ការឈឺចាប់របស់គាត់បានទេ ។ ប្រជាជនដែលរស់នៅទីក្រុងមានលុយ ដូច្នេះ គេអាចបំភ្លេចការតស៊ូនៅអតីកាលរបស់គេបាន ប៉ុន្តែអ្នកដែលរស់នៅជន

បទនឹងមិនបំភ្លេចពីរឿងនេះទេ ។ ខ្ញុំនឹងមិនសប្បាយប្រសិនបើ អៀង សារី ត្រូវបានដោះលែង ។ អៀង សារី ប្រហែលជាមិនបានប្រព្រឹត្តិឧក្រិដ្ឋកម្មដោយខ្លួនឯងទេ ប៉ុន្តែគាត់ត្រូវទទួលខុសត្រូវពីព្រោះគាត់គឺជាអ្នកបញ្ជាពីក្រោយ ។

ហ៊ុយ យុទ្ធ មកពីខេត្តកំពត គាត់បានបាត់បង់សាច់ញាតិ១០នាក់នៅរបបខ្មែរក្រហម ហើយគាត់ចង់ឲ្យតុលាការដំណើរ និងបញ្ចប់កាត់ក្តីឲ្យបានលឿន ។ «ប្រសិនបើមានការពន្យារពេលយូរពេក មេដឹកនាំខ្មែរក្រហមប្រហែលជានឹងស្លាប់ ។ ខ្ញុំពិតជាមានអារម្មណ៍សប្បាយចំពោះការកាត់ទោសនេះណាស់ ពីព្រោះការកាត់សេចក្តីនេះ គឺសម្រាប់អនាគតរបស់ក្មេងជំនាន់ក្រោយ» ។

ដោយយោងទៅតាមការបដិសេធមិនដោះលែង អៀង សារី គោ សុផល ដែលចង់ឲ្យអៀង សារី ស្លាប់ មានអារម្មណ៍ថា ព្រលឹងនៃសមាជិកគ្រួសាររបស់គាត់ទទួលបានការសងសឹកហើយ ។

ហ៊ុយ យុទ្ធ ជឿថា «ទោះបីជាកំហឹងរបស់គាត់នឹងមិនសាបរលាប ប៉ុន្តែយុត្តិធម៌តាមផ្លូវច្បាប់អាចបន្ធូរបន្ថយកំហឹងនោះបាន» ។